ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម | អគ្គនាយកដ្ឋានពន្ធដារ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | បេឡាជាតិសន្តិសុខសង្គម | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ក្រសួងមហាផ្ទៃ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" | សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា

ថ្ងៃ ចន្ទ ៥ កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២៤

សេចក្តីប្រកាសព័ត៌មានរួម
ស្តីពី
"ការដាក់ដំណើរការនូវមុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន/សហគ្រាសចំនួន ៥ លើប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន"

ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចរបស់រាជរដ្ឋាភិបាល សូមជម្រាបជូនសាធារណជន ជ្រាបថា ផ្អែកតាមវិធានការរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៣ កន្លងទៅ ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, *មុខងារចុះបញ្ជីកែប្រែព័ត៌មាន ក្រុមហ៊ុន/សហគ្រាសចំនួន ៥ នឹងត្រូវដាក់ដំណើរការជាផ្លូវការ ចាប់ពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២៤ នេះតទៅ លើប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (Single Portal) ។ មុខងារទាំង ៥ នេះរួមមាន (១) កែប្រែព័ត៌មានលម្អិតអាសយដ្ឋាន ទីស្នាក់ការចុះបញ្ជី, (២) កែប្រែលក្ខន្តិកៈក្រុមហ៊ុន, (៣) កែប្រែសកម្មភាពអាជីវកម្ម, (៤) តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ និង (៥) កែប្រែព័ត៌មានគណនីធនាគារ ។ ដំណើរការនេះនឹងត្រូវធ្វើឡើងតាម អនឡាញទាំងស្រុង ដោយមិនមានតម្រូវការវត្តមានទៅផ្ទាល់ដល់ទីកន្លែងទៀតទេ ។*

កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ កន្លងទៅ, រាជរដ្ឋាភិបាលកម្ពុជាបានកត់ត្រានូវដំណើរឌីជីថលូបនីយកម្មសេវាសាធារណៈមួយយ៉ាងសំខាន់ នោះគឺការដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១ សំដៅបង្កបរិយាកាសអំណោយផលដល់ការធ្វើធុរកិច្ចនៅកម្ពុជា និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាលើឆាកអន្តរជាតិ ។ ដំណើរនេះត្រូវបានវិស័យឯកជន សារព័ត៌មានជាតិ និងអន្តរជាតិ បង្ហាញការចាប់អារម្មណ៍ខ្ពស់ ដោយហេតុថាប្រព័ន្ធនេះមិនត្រឹមតែបញ្ចូលសេវាចុះបញ្ជីអាជីវកម្មចូលក្នុងប្រព័ន្ធអនឡាញប៉ុណ្ណោះទេ ប៉ុន្តែបានប្រែក្លាយការចុះបញ្ជីអាជីវកម្មនេះ ផ្អែកលើគោលការណ៍ចំនួន ៣ រួមមាន ៖ (១) ការកាត់បន្ថយចំណាយ, (២) ការកាត់បន្ថយថិរវេលា, និង (៣) ការកាត់បន្ថយនីតិវិធីស្មុគស្មាញ ។

ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ត្រូវបានពង្រីកវិសាលភាពរហូតដល់ដំណាក់កាលទី ៣ ហើយ ដែលដំណាក់កាលទី ១ ជាការចុះបញ្ជីអាជីវកម្មជាខ្សែច្រវ៉ាក់ និងដំណាក់កាលទី ២ និងទី ៣ ជាការស្នើសុំអាជ្ញាបណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រជំនាញ និងឯកសារពាក់ព័ន្ធនឹងការធ្វើធុរកិច្ច ។ ការពង្រីកវិសាលភាពនេះត្រូវបានធ្វើជាអន្លើៗ ដោយការជ្រើសរើសយកសេវាកម្មណាមួយមកដាក់ចូលក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ ត្រូវធ្វើឡើងផ្អែកលើតម្រូវការខ្ពស់របស់វិស័យឯកជន និងហានិភ័យទាប ។ ទន្ទឹមនឹង

ការបញ្ចូលសេវាកម្មទៅក្នុងប្រព័ន្ធ, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក៏ត្រូវបានបន្ថែមមុខងារផ្សេងៗជាច្រើន សំដៅបង្កភាពងាយស្រួលដល់ធុរជន រួមទាំងមុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន/សហគ្រាស ចំនួន ៥ ដែលត្រូវបានដាក់ដំណើរការក្នុងថ្ងៃនេះ។

ការបញ្ចូលមុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន/សហគ្រាសជាសមិទ្ធផលថ្មីរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់វិស័យឯកជន។ ទន្ទឹមនេះ, ក្នុងឆ្នាំ ២០២៤, ក្រុមការងារនឹងរៀបចំដាក់ដំណើរការជាបន្តបន្ទាប់ នូវមុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន/សហគ្រាសផ្សេងទៀត រួមជាមួយនឹងការបញ្ចូលសេវាសាធារណៈគន្លឹះសំខាន់ៗ ពាក់ព័ន្ធនឹងការធ្វើធុរកិច្ចថ្មីៗបន្ថែមទៀត មកក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ។

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងមុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន/សហគ្រាស និងប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, សូមចូលទៅកាន់គេហទំព័រ www.registrationservices.gov.kh ឬទាក់ទងមកកាន់លេខទូរស័ព្ទទាន់ហេតុការណ៍ 081 888 296, ទំព័រហ្វេសប៊ុក Online Business Registration Service ឬអ៊ីម៉ែល registrationservices@mef.gov.kh រៀងរាល់ថ្ងៃ និងម៉ោងធ្វើការ។